# វិទ្យាស្ថានសភាកម្ពុជា

PARLIAMENTARY INSTITUTE OF CAMBODIA

STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺៈ

- សហព័ន្ធស្រូវអង្ករកម្ពុជា មានករណីជំទាស់តវ៉ាជាមួយសហភាពអឺរ៉ុប
- ទីប្រឹក្សាផ្នែកសេដ្ឋកិច្ចរបស់ប្រទេសចិន បានផ្តល់អនុសាសន៍ឲ្យមានការពិនិត្យមើលលើកំណើនដែលមានលក្ខណៈថយចុះ សម្រាប់ឆ្នាំ២០១៩
- ធនាគារសហព័ន្ធ បង្កើនអត្រាការប្រាក់ ប៉ុន្តែទីផ្សារបន្ថយការរំពឹងទុកសម្រាប់ការតម្លើងនេះ ក្នុងឆ្នាំ២០១៩

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### សហព័ន្ធស្រូវអង្ករកម្ពុជា មានករណីជំទាស់តវ៉ាជាមួយសហភាពអឺរ៉ុប

យោងតាមរបាយការណ៍របស់កាសែតភ្នំពេញប៉ុស្តិ៍ បានឱ្យដឹងថា សហព័ន្ធស្រូវអង្ករកម្ពុជា(CRF) បានទាមទារឱ្យសហភាពអឺរ៉ុបធ្វើវិសោធនកម្មលើសំណើរបស់ខ្លួនទាក់ទងនឹងពន្ធលើការនាំចូលអង្ករ (ដែលហៅថា ចំនុច/លក្ខណ្ឌការពារ Safeguard clause) ព្រោះវាអាចប៉ះពាល់ដល់ឧស្សាហកម្មអង្កររបស់កម្ពុជា។

នៅក្នុងលក្ខខណ្ឌការពារដែលមានចែងក្នុងសន្ធិសញ្ញាទីក្រុងរ៉ូម ដែលបានបង្កើតសហភាពអឺរ៉ុប បានចែងថា នៅពេលដែលការនាំចូលពីប្រទេសទីបីមានផលប៉ះពាល់ដល់តុល្យភាពពាណិជ្ជកម្មរបស់រដ្ឋជាសមាជិកនៃសហភាពអឺរ៉ុប រដ្ឋនោះអាចស្នើសុំឱ្យគណៈកម្មការអឺរ៉ុបដាក់របាំងពាណិជ្ជកម្មបាន។ ប្រទេសអ៊ីតាលី និងអេស្ប៉ាញបានស្នើសុំការដាក់លក្ខណ្ឌការពារនេះចំពោះកម្ពុជានិងមីយ៉ាន់ម៉ា។ ប្រសិនបើសេចក្តីព្រាងច្បាប់ដំបូងនៃលក្ខណ្ឌការពាររបស់សហភាពអឺរ៉ុបត្រូវបានអនុម័ត កាតព្វកិច្ចពន្ធគយនឹងត្រូវបានកំណត់ដល់១៧៥ អឺរ៉ូ (១៩៨ ដុល្លារអាមេរិក) ក្នុងមួយតោន នៅឆ្នាំដំបូង ១៥០អឺរ៉ូ នៅឆ្នាំទី២ និង ១២៥អឺរ៉ូ នៅឆ្នាំបន្ទាប់។ សហភាពអឺរ៉ុបមិនទាន់បានធ្វើសេចក្តីសម្រេចចុងក្រោយថាតើពួកគេនឹងអនុវត្តលក្ខខណ្ឌការពារនៅឡើយទេ។

លោក សុងសារ៉ន អគ្គនាយកក្រុមហ៊ុន Amru Rice ដែលជាអ្នកនាំអង្ករចេញធំជាងគេនៅកម្ពុជាបានអះអាងថា ការថយចុះនៃឧស្សាហកម្មអង្កររបស់ប្រទេសអ៊ីតាលីនិងអេស្ប៉ាញ ដែលជាមូលហេតុដំបូងនៃការពិនិត្យពន្ធគយឡើងវិញ គឺមិនបណ្តាលមកពីកម្ពុជាឡើយ ព្រោះថា ៧៥%នៃការនាំចេញអង្ករកម្ពុជាទៅកាន់សហភាពអឺរ៉ុបគឺជាអង្ករក្រអូបដែលមិនអាចដាំដុះនៅក្នុងប្រទេសរបស់ពួកគេឡើយ។

## តារាងប្រចាំសប្តាហ៍៖ ការអនុវត្តថវិកាឆ្នាំ២០១៨

តារាងក្នុងសប្តាហ៍នេះ បង្ហាញពីការអនុវត្តថវិការបស់ប្រទេសកម្ពុជាក្នុងរយៈពេល១០ខែដំបូងនៃឆ្នាំ២០១៨ ធៀបជាមួយនឹងគោលដៅដែលបានដាក់ចេញនៅក្នុងច្បាប់ថវិកាឆ្នាំ២០១៨។

លទ្ធផលថវិកាឆ្នាំ២០១៨ មានលក្ខណៈវិជ្ជមាន ដែលមួយផ្នែកគឺមកពីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលធ្វើឡើងក្នុងគោលបំណងពង្រឹង និងពង្រីកប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការកៀរគរចំណូល និងការគ្រប់គ្រងការចំណាយ។

គិតត្រឹមខែតុលានេះ សមតុល្យគណនីចរន្តមានអតិរេកចំនួន ៤ ៥៨៧ ប៊ីលានរៀល ដែលខ្ពស់ជាងអតិរេកគណនីចរន្តដែលបានធ្វើការរំពឹងទុកក្នុងច្បាប់ថវិកាឆ្នាំ២០១៨ ប្រមាណ២០៤,៦%។ ទោះបីជាការចំណាយសម្រាប់ប៉ុន្មានខែចុងឆ្នាំមានសារៈសំខាន់ខ្លាំងយ៉ាងណាក៏ដោយ ក៏គ្រប់សញ្ញាទាំងអស់បានចង្អុលបង្ហាញថា លទ្ធផលសម្រាប់ឆ្នាំ២០១៨ទាំងមូល គឺសម្រេចលើសពីការរំពឹងទុក។

### ការអនុវត្តថវិកា ជាសង្ខេបសម្រាប់១០ខែដំបូង ឆ្នាំ២០១៨

| ពិពណ៌នា | ច្បាប់ ថវិកា ឆ្នាំ ២០១៨ (ប៊ីលានរៀល) | ជាក់ស្តែង (មករា-តុលា) (ប៊ីលានរៀល) | ជាក់ស្តែង / ច្បាប់ ថវិកាឆ្នាំ ២០១៨ |
|---|---|---|---|
| **I.ចំណូលក្នុងស្រុក** | **១៧ ៦៤០,២** | **១៥ ៦៥៦,៣** | **៨៨,៨%** |
| *1.ចំណូលចរន្ត* | *១៧ ៤៦០,០* | *១៥ ៥២៦,០* | *៨៨,៩%* |
| ចំណូលពន្ធ | ១៥ ០៧៥,៦ | ១៣ ៧៣៤,៥ | ៩១,១% |
| ចំណូលមិនមែនពន្ធ | ២ ៣៨៤,៤ | ១ ៧៩១,៦ | ៧៥,១% |
| *2.ចំណូលមូលធន* | *១៨០,១៩* | *១៣០,៣* | *៧២,៣%* |
| **II.ចំណាយ សរុប** | **២២ ៦៩០,៩** | **១៤ ៨១៧,៥** | **៦៥,៣%** |
| *1.ចំណាយចរន្ត* | *១៥ ២១៨,២* | *១០ ៩៣៩,២* | *៧១,៩%* |
| ប្រាក់បៀវត្ស | ៧ ៩១៤,៩ | ៦ ៣៧២,២ | ៨០,៥% |
| មិនមែនប្រាក់បៀវត្ស | ៧ ៣០៣,២ | ៤ ៥៦៦,៩ | ៦២,៥% |
| *2.ចំណាយមូលធន* | *៧ ៤៧២,៧* | *៣ ៨៧៨,៣* | *៥១,៩%* |
| ហិរញ្ញប្បទានក្នុងស្រុក | ២ ៩២៥,៨ | ២ ១៩៣,៧ | ៧៥,០% |
| ជំនួយពីខាងក្រៅ | ៤ ៥៤៦,៩ | ១ ៦៨៤,៦ | ៣៧,១% |
| **សមតុល្យគ ណនីចរន្ត** | **២ ២៤១,៨** | **៤ ៥៨៦,៩** | **២០៤,៦%** |
| ***III.ហិរញ្ញប្បទាន*** | ***៥ ០៥០,៧*** | ***(៨៣៨,៨)*** | ***-១៦,៦%*** |
| *1.ហិរញ្ញប្បទានក្រៅប្រទេស* | ៤ ០៥៩,៦ | ១ ២៤៨,១ | ៣០,៨% |
| ទ្រទ្រង់ថវិកា | ២៥០,០ | ២១២,៤ | ៨៥.០០% |
| ជំនួយគម្រោង | *៤ ៥៤៦,៩* | *១ ៦៥០,០* | *៣៦,៣%* |
| *2.ហិរញ្ញប្បទានក្នុងស្រុក* | - | ១៥៥,៩ | |

ប្រភព៖ របាយការណ៍អនុវត្តថវិការដ្ឋ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ទីប្រឹក្សាសេដ្ឋកិច្ចរបស់ប្រទេសចិន បានផ្តល់អនុសាសន៍ឲ្យបន្ទាបការវាយតម្លៃកំណើនសេដ្ឋកិច្ចឆ្នាំ២០១៩

ខណៈពេលមានជំនួបរវាងអ្នកធ្វើគោលនយោបាយជាន់ខ្ពស់របស់ប្រទេសចិនក្នុងសន្និសិទសេដ្ឋកិច្ចប្រចាំឆ្នាំ ទីប្រឹក្សា និងអ្នកផ្តល់គំនិត(think tanks)របស់រដ្ឋាភិបាល បានផ្តល់អនុសាសន៍ថាការរំពឹងទុកនៃកំណើនសេដ្ឋកិច្ចឆ្នាំ២០១៩ ត្រូវធ្វើការពិនិត្យសារឡើងវិញ ដោយរក្សាគោលដៅត្រឹមចន្លោះ ៦,០%ទៅ ៦,៥%សម្រាប់ឆ្នាំ២០១៩ ធៀបនឹង៦,៥%នៅក្នុងឆ្នាំ២០១៨។ ការបន្ថយការរំពឹងទុកនៃកំណើនសេដ្ឋកិច្ចនេះ គឺបណ្តាលមកពីបញ្ហាជម្លោះពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិក។ (សារព័ត៌មានរ៉ូតទ័រ)

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### ធនាគារសហព័ន្ធបង្កើនអត្រាការប្រាក់ ប៉ុន្តែទីផ្សារបន្ថយការរំពឹងទុកសម្រាប់ការដំឡើងក្នុងឆ្នាំ២០១៩

ធនាគារកណ្តាលសហរដ្ឋអាមេរិក បានបង្កើនអត្រាការប្រាក់ក្នុងសប្តាហ៍នេះពីចន្លោះ២,២៥ ទៅ២,៥០ភាគរយ។ ទោះជាយ៉ាងណា អ្នកវិនិយោគ បានបកស្រាយរបាយការណ៍គោលនយោបាយរបស់ធនាគារកណ្តាលថា មានភាពបន្ធូរបន្ថយនូវសក្តានុពលក្នុងការដំឡើងនៅឆ្នាំក្រោយ។ រវាងរបាយការណ៍នេះ និងសេចក្តីថ្លែងការរបស់ប្រធានាធិបតី ដែលបានរិះគន់ធនាគារកណ្តាលចំពោះជំហរគោលនយោបាយធ្ងន់ធ្ងររបស់ខ្លួន ទីផ្សារនាពេលអនាគតបង្ហាញថាពាណិជ្ជករ បច្ចុប្បន្នកំពុងតែភ្នាល់ថាធនាគារកណ្តាលនឹងមិនដំឡើងអត្រាការប្រាក់ឡើយក្នុងឆ្នាំក្រោយ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ស្របពេលដែលភ្នាក់ងារស្ថិតិជាច្រើននឹងសម្រាកសម្រាប់ពិធីបុណ្យណូអែល ដូច្នេះសប្តាហ៍នេះជាពេលសម្រាប់ការចេញផ្សាយទិន្នន័យអាស៊ី និងប្រទេសដែលជាសមាជិកអាស៊ាន។ ទិន្នន័យដែលនឹងបង្ហាញក្នុងសប្តាហ៍នេះរួមមាន អត្រាអតិផរណា ផ.ស.

ស.នៅក្នុងប្រទេសវៀតណាម អត្រានិកម្មភាពក្នុងប្រទេសថៃ ទិន្នន័យថវិកាក្នុងប្រទេសហ្វីលីពីន និងតុល្យភាពពាណិជ្ជកម្មក្នុងប្រទេសប្រ៊ុយណេ។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃច័ន្ទ ទី២៤ ខែធ្នូ ឆ្នាំ២០១៨</u>

- សន្ទស្សន៍ក្នុងការវាយតម្លៃសេដ្ឋកិច្ចរបស់ម៉ាឡេស៊ី សម្រាប់ខែតុលា
- អត្រាអតិផរណារបស់សង្ហបុរី សម្រាប់ខែ វិច្ឆិកា
- ការលក់រាយ របស់តៃវ៉ាន់ សម្រាប់ខែវិច្ឆកា
- ការដេញថ្លៃ របស់អាមេរិក ៣ខែនិង៦ខែ (U.S. 3 month and 6 month bill auctions)

<u>ថ្ងៃអង្គារ ទី២៥ ខែធ្នូ ឆ្នាំ២០១៨</u>

- ផលិតកម្មឧស្សាហកម្មរបស់ថៃ សម្រាប់ខែវិច្ឆិកា
- សន្ទស្សន៍នាំមុខក្នុងការវាយតម្លៃសេដ្ឋកិច្ចជប៉ុន សម្រាប់ខែតុលា

<u>ថ្ងៃពុធ ទី២៦ ខែធ្នូ ឆ្នាំ២០១៨</u>

- កិច្ចប្រជុំគោលនយោបាយរូបិយវត្ថុរបស់ធនាគាជប៉ុន
- ការវិនិយោគដោយផ្ទាល់ពីបរទេសរបស់វៀតណាម សម្រាប់ខែវិច្ឆិកា
- អត្រានៃភាពអត់ការងាធ្វើរបស់ថៃ សម្រាប់ខែវិច្ឆិកា
- ផលិតកម្មឧស្សាហកម្ម សឹង្ហបុរី សម្រាប់ខែ វិច្ឆិកា

<u>ថ្ងៃព្រហស្បតិ៍ ទី២៧ ខែធ្នូ ឆ្នាំ២០១៨</u>

- ទំនុកចិត្តអ្នកប្រើប្រាស់ កូរ៉េខាងត្បូង សម្រាប់ខែធ្នូ
- ប្រាក់ចំណេញរបស់ឧស្សហកម្មរបស់ចិន សម្រាប់ខែវិច្ឆិកា
- តុល្យភាពពាណិជ្ជកម្ម របស់ហុងកុង សម្រាប់ខែវិច្ឆិកា
- តម្លៃលំនោដ្ឋានរបស់ជប៉ុន សម្រាប់ខែវិច្ឆិកា
- តុល្យភាពថវិកា របស់ហ្វីលីពីន
- ការប្រកាសភាពអត់ការងារធ្វើរបស់អាមេរិក ២២/ធ្នូ
- ទំនុកចិត្តអ្នកប្រើប្រាស់របស់អាមេរិក សម្រាប់ខែធ្នូ
- ការលក់ផ្ទះថ្មីរបស់អាមេរិក សម្រាប់ខែវិច្ឆិកា

<u>ថ្ងៃសុក្រ ទី២៨ ខែធ្នូ ឆ្នាំ២០១៨</u>

- ទំនុកចិត្តទៅលើពាណិជ្ជកម្មរបស់កូរ៉េខាងត្បូង សម្រាប់ខែធ្នូ
- ផលិតកម្មឧស្សាហកម្មកូរ៉េខាងត្បូង សម្រាប់ខែវិច្ឆិកា
- អតិផរណាសន្ទស្សន៍តម្លៃអ្នកប្រើប្រាស់ ទីក្រុងតូក្យូ (TOKYO) ប្រទេសជប៉ុន សម្រាប់ខែធ្នូ
- អត្រាអត់ការងាររបស់ជប៉ុន សម្រាប់ខែ វិច្ឆិកា
- ផលិតកម្មឧស្សាហកមរបស់ជប៉ុន សម្រាប់ខែធ្នូ
- ការមកដល់ភ្ញៀវទេសចរណ៍របស់វៀតណាម សម្រាប់ខែធ្នូ
- អត្រាកំណើន ផ.ស.សវៀតណាម សម្រាប់ខែធ្នូ
- គណនីចរន្តរបស់ថៃ សម្រាប់ខែវិច្ឆិកា
- តុល្យភាពពាណិជ្ជកម្មរបស់ព្រុយណេ សម្រាប់ខែតុលា
- ការវិនិយោគដោយផ្ទាល់ពីបរទេស របស់វៀតណាម សម្រាប់ខែ ធ្នូ